ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨៩
ថ្ងៃទី១៦-០១-២០១៧
សាលដីកា
លេខ: ៤៨ក្រ III "ន"
ចុះថ្ងៃទី០៣-០៨-២០១៧

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រឹត្យលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-៧-២០១៤ បានបើកសវនាការជាសាធារណ:នៅសាលាឧទ្ធរណ៍នាថ្ងៃទី ២៤-០៧-២០១៧ ដោយមានសមាសភាព ដូចតទៅ:

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ:</u>

លោកស្រី [redacted] ជាប្រធាន
ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោកស្រី [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងក្ដីព្រហ្មទណ្ឌលេខ: ៨៩ ចុះថ្ងៃទី ១៦-០១-២០១៧ រវាង:

១.ឈ្មោះ [redacted] ហៅ [redacted]ភទប្រុស កើតឆ្នាំ១៩៩២ ជាតិខ្មែរ មុខរបររកស៊ីឈ្នួលធ្វើម្ហូបការ កំរិតវប្បធម៌ថ្នាក់ទី១២ ទីកន្លែងកំណើតភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted] (ស) ម្ដាយឈ្មោះ[redacted]) នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី ០៥-០៣-២០១៦)។ (ប្ដឹងឧទ្ធរណ៍)

២.ឈ្មោះ[redacted]ៅ [redacted]ទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិខ្សាច់ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះសង់ថ្មី ផ្លូវលំ



Scanned by CamScanner

ក្រុមទី៥ ភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted] ម្ដាយឈ្មោ[redacted]) នៅលីវ ជានីតិជន (គេចខ្លួន)។

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខវត្តព្រែកប្រា ផ្លូវលេខ៣៦៩ ស្ថិតនៅភូមិអូរអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ដើមបណ្ដឹងរដ្ឋប្បវេណី៖

ឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរជាងឈើ ទីកន្លែងកំណើតសង្កាត់សេរីភាព ក្រុងតាខ្មៅ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នភូមិតាខ្មៅ ឃុំតាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

អំពីអង្គហេតុ

កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១៨និង៣០នាទី ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] និងមិត្តភក្តិកំពុងជិះម៉ូតូចេញពីធ្វើការមកដល់ចំណុចមុខវត្តព្រែកប្រា ផ្លូវលេខ៣៦៩ ស្ថិតនៅភូមិអូរអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ស្រាប់តែមានជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជាអ្នកជិះពីក្រោយ និងឈ្មោ[redacted]ភេទប្រុស ជាអ្នកឌុបបានជិះម៉ូតូមួយគ្រឿងម៉ាកC125 ជិះម៉ូតូមកអែបម៉ូតូដើមបណ្ដឹងរដ្ឋប្បវេណី ហើយជនជាប់ចោទឈ្មោះ[redacted]បាន ធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីជនរងគ្រោះបណ្ដាលឱ្យដួលម៉ូតូទាំងពីរគ្រឿង តែត្រូវបានដើមបណ្ដឹងរដ្ឋប្បវេណីស្រែករួចក៏ឃាត់ខ្លួនបានជនជាប់ចោទឈ្មោ[redacted]ហើយធ្វើតេស្តគ្រឿងញៀនគឺលទ្ធផលគ្រឿងញៀន ចំណែកឈ្មោ[redacted]គេចខ្លួនបាត់។

-បានឃើញ:សាលក្រមព្រហ្មទណ្ឌលេខ: ៥៤៩ ក្រ១ "ន" ចុះថ្ងៃទី០៩-១២-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចខាងក្រោម៖

១.ឱ្យជនជាប់ចោទឈ្មោះ [redacted]ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ រួចផុតពីការចោទប្រកាន់ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខវត្តព្រែកប្រា ផ្លូវលេខ៣៦៩ ស្ថិតនៅភូមិអូរអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិផ្ដន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ផ្តន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ [redacted]ហៅ ទុំ ភេទប្រុស កើតឆ្នាំ១៩៩២ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ (បួន)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវ



Scanned by CamScanner

សារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខវត្តព្រែកប្រា ផ្លូវលេខ៣៨៦ ស្ថិតនៅភូមិអូរអណ្តូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.ឈ្មោះ [redacted] ឆាលី ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥(ប្រាំ)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខវត្តព្រែកប្រា ផ្លូវលេខ៣៨៦ ស្ថិតនៅភូមិអូរអណ្តូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.វត្ថុតាងដែលចាប់យកមាន៖

ក.ម៉ូតូមួយគ្រឿងម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1CM 5171 មានលេខតួ និងលេខម៉ាស៊ីន 8910170(មិនប្រក្រតី) សម្រេចរឹបអូសជាសម្បត្តិរដ្ឋ តាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

ខ.ទូរស័ព្ទដៃមួយគ្រឿងម៉ាក CAMFONE បែកអេក្រង់ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួនមួយសន្លឹក(ឈ្មោះ ស ចាន់ធារ:) សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ តាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤.បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ឆាលី ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

៥.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] រួមគ្នាសងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន២០០(ពីររយ)ដុល្លារអាមេរិក ។ ការទាមទារលើសពីនេះបដិសេធចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញ: ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧-១២-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៤៩ "ខ" ក្រ១ ចុះថ្ងៃទី០៩-១២-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ របាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី០៣-០៥-២០១៧ ។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី ១១-០៥-២០១៧ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)



Scanned by CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណី [redacted] (អវត្តមាន)

-មេធាវីការពារសិទ្ធិជនជាប់ចោទ [redacted] (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]នឆ្លើយថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ ការដែលខ្លួនប្ដឹងឧទ្ធរណ៍នេះ មូលហេតុសាលាដំបូងដាក់ទោសខ្លួនធ្ងន់ពេក ។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ការប្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទគឺ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ហើយជនជាប់ចោទក៏បានឆ្លើយសារភាព ព្រមទាំងមានសាក្សីក៏បានបញ្ជាក់ដែរថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសពិតមែន ដូច្នេះសាលក្រមរបស់សាលាដំបូង សម្រេចត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានសន្និដ្ឋានការពារថា៖ ថ្វីត្បិតតែកូនក្ដីខ្លួនបានប្រព្រឹត្តបទល្មើសមែនតែមិនមានចេតនាធ្វើឱ្យជនរងគ្រោះមានរបួសទេ ដូច្នេះសូមសំណូមពរឱ្យក្រុមប្រឹក្សាកែប្រែបទចោទមកជាបទល្មើស លួច វិញ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៧-១២-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted]ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៥៤៩ ក្រ១ "ខ" ចុះថ្ងៃទី០៩-១២-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមច្បាប់ យោងតាមមាត្រា ៣៧៣ ,៣៧៥ ,៣៧៦ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះបានជាសមត្ថកិច្ច។

២-ក្រោយការសួរដេញដោលនាពេលសវនាការ ក៏ដូចជាការពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា៖ កាលពីថ្ងៃទី០២-០៣-២០១៦ វេលាម៉ោង ១៨:៣០នាទី ជនរងគ្រោះឈ្មោ[redacted]និងមិត្តភក្តិកំពុងជិះម៉ូតូចេញពីធ្វើការមកដល់ចំណុចវត្តព្រែកប្រា ផ្លូវលេខ៣៦៩ ស្ថិតនៅភូមិអូរអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ស្រាប់តែមានជនជាប់ចោទឈ្មោ[redacted]ទប្រុស អាយុ២៥ឆ្នាំ ជាអ្នកជិះពីក្រោយ និងឈ្មោះ [redacted]ភេទប្រុស ជាអ្នកឌុបបានជិះម៉ូតូមួយគ្រឿងម៉ាកC125 មកអែប



Scanned by CamScanner

ម៉ូតូដើមបណ្ដឹងរដ្ឋប្បវេណី ហើយជនជាប់ចោទឈ្មោះ [redacted] បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីជនរងគ្រោះបណ្ដាលឱ្យដួលម៉ូតូទាំងពីរគ្រឿង តែត្រូវបានដើមបណ្ដឹងរដ្ឋប្បវេណីស្រែករួចក៏ឃាត់ខ្លួនបានជនជាប់ចោទឈ្មោះ [redacted] ហើយធ្វើតេស្តទឹកនោមគឺលទ្ធផលមានសារធាតុញៀន ចំណែកឈ្មោះ [redacted] រត់គេចខ្លួនបាត់ ។

៣-សកម្មភាពរបស់ជនជាប់ចោទ គឺជាទម្រង់មួយនៃអំពើដែលមានធាតុផ្សំនៃបទល្មើស និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់សារធាតុញៀនខុសច្បាប់ ដែលច្បាប់បានចែង និងតម្រូវឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដូចមានក្នុងសំអាងហេតុ នៃសាលក្រមព្រហ្មទណ្ឌលេខ៥៤៩ ក្រ១ "ន" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បានឯកភាព ។ ហេតុនេះ សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ មិនលើកយកសំអាងហេតុដែលនេះមកធ្វើការបញ្ជាក់ជាថ្មីទៀតទេ ។

៤-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ ការដែលខ្លួនប្ដឹងឧទ្ធរណ៍នេះ មូលហេតុសាលាដំបូងដាក់ទោសខ្លួនធ្ងន់ពេក ។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ នឹងពិចារណា ។

៥-តំណាងមហាអយ្យការបានសន្និដ្ឋានថា៖ ការប្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទគឺធ្វើឡើងត្រឹមត្រូវតាមច្បាប់ ហើយជនជាប់ចោទបានឆ្លើយសារភាព ព្រមទាំងមានសាក្សីក៏បានបញ្ជាក់ដែរថាជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសពិតមែន ដូច្នេះសាលក្រមរបស់សាលាដំបូង សម្រេចត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាសម្រេចតម្កល់ទុកជាបានការ ។ ការលើកឡើងនេះមានមូលហេតុគ្រប់គ្រាន់ដែលអាចឱ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិចារណាបាន ។

៦-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានសន្និដ្ឋានការពារថា៖ ថ្វីត្បិតតែកូនក្ដីខ្លួនបានប្រព្រឹត្តបទល្មើសមែនតែមិនមានចេតនាធ្វើឱ្យជនរងគ្រោះមានរបួសទេ ដូច្នេះសូមសំណូមពរឱ្យក្រុមប្រឹក្សាកែប្រែបទចោទមកជាបទល្មើស លួច វិញ ។ ការលើកឡើងនេះពុំមានមូលហេតុតាមផ្លូវច្បាប់ដែលអាចឱ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ធ្វើការពិចារណាបានទេ ។

៧-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខវត្តព្រែកប្រា ផ្លូវលេខ៣៦៩ ស្ថិតនៅភូមិអូរអណ្ដូង សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-សាលក្រមព្រហ្មទណ្ឌលេខ៥៤៩ ក្រ១ "ន" ចុះថ្ងៃទី០៩-១២-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។



Scanned by CamScanner

<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧-១២-២០១៦ របស់ឈ្មោះ [redacted] ជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៥៤៩ ក្រ១ "ខ" ចុះថ្ងៃទី០៩-១២-២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៤-០៧-២០១៧ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣-០៨-២០១៧ ។

ទុក្ខសិទ្ធិប្តឹងតវ៉ាតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេ[redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ, ថ្ងៃទី.......... ខែ.......... ឆ្នាំ២០១៧

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned by CamScanner